សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង

http://www.DELGOSEA.eu.

DELGOSEA

Partnership for Democratic Local Governance in Southeast-Asia



Non-State Actors and Local Authorities in Development - Actons in Partner Countries (Multi Country) for Non-State Actors

## ការិយាល័យសម្របសម្រួលគម្រោងតាមអស័យដ្ឋានខាងក្រោម :


c/o Konrad-Adenauer-Stiftung
5/F Cambridge Center Bldg.
108 Tordesillas cor.. Gallardo Sts.
Salcedo Village, Makati City, Manila, Philippines
Tel: +63.2.4037697
Fax: +63.2.8936199
E-mail: Communications-Office@delgosea.eu


គម្រោង DELGOSEA ត្រូវបានរៀបចំឡើងដោយ Konrad-Adenauer-Stiftung(KAS) ដោយមានកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយនឹងដៃគូនានា ដែលរួមមាន : សមាគមទីក្រុងនៃប្រទេសវៀតណាម (ACVN) មូលនិធិរដ្ឋាភិបាលមូលដ្ឋាន របស់ប្រទេសហ្វីលីពីន (LOGODEF) សម្ព័ន្ធភាពឃុំ/សង្កាត់ នៃប្រទេសកម្ពុជា (NLC/S) វិទ្យាស្ថានបរិស្ថាននៃប្រទេសថៃឡង់ (TEI) សហព័ន្ធទីក្រុង និង រដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក (UCLG-SPAC) និង សមាគមស្រុករបស់ប្រទេសឥណ្ឌូនេស៊ី (APKASI) ។


កម្មវិធីនេះត្រូវបានអនុវត្តដោយ Konrad-Adenauer-Stiftung ។ ទស្សនៈដែលបានបង្ហាញក្នុងឯកសារនេះ មិនប្រាកដថាជាទស្សនៈរបស់ស្ទងការសហភាពអឺរ៉ុបនោះទេ ។


សហភាពអឺរ៉ុប មានសមាជិក២៧រដ្ឋ ដែលបានធ្វើការសម្រេចចិត្តភ្ជាប់ជាមួយគ្នានូវបច្ចេកទេស ធនធាន និងគោលដៅរួមរបស់ខ្លួន។ អស់រយៈពេលនៃការពង្រីកសមាជិកភាព ៥០ឆ្នាំកន្លងមក សហភាពអឺរ៉ុបបានបង្កើតឡើងនូវតំបន់មួយដែលមានស្ថិរភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទន្ទឹមនឹងការរក្សាបាននូវវប្បធម៌ខុសៗគ្នា ការអធ្យាស្រ័យ និងសេរីភាពទៅតាមប្រទេសនីមួយៗ ។

សហភាពអឺរ៉ុបមានការប្តេជ្ញាចិត្ត ដើម្បីចែករំលែកលទ្ធផល និងគុណតម្លៃរបស់ខ្លួន ជាមួយនឹងបណ្តាប្រទេស និងប្រជាពលរដ្ឋ ដែលរស់នៅក្រៅទឹកដីរបស់ខ្លួន។


គម្រោងនេះត្រូវបានធ្វើសហហិរញ្ញប្បទានដោយសហភាពអឺរ៉ុប


# ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍

www.DELGOSEA.eu

DELGOSEA

**DELGOSEA**

**Partnership for Democratic Local Governance in Southeast-Asia**







## អំពីគម្រោង

គម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍ គឺជាបណ្តាញនៃសមាគមអាជ្ញាធរមូលដ្ឋាន រដ្ឋអំណាចមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងវិទ្យាស្ថានអប់រំនានាក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពិន ថៃឡង់ និងវៀតណាម ។

## គោលបំណងគម្រោង

- ចូលរួមធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរស់នៅ នៃក្រុមជនទន់ខ្សោយក្នុងអាស៊ីអាគ្នេយ៍ តាមរយៈការជំរុញនូវការចូលរួមរបស់ក្រុមទាំងនេះនៅក្នុងដំណើរការធ្វើផែនការ និងការសម្រេចចិត្តនៅមូលដ្ឋាន ។
- ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង ឥរិយាបទ និងការអនុវត្តនានារបស់សមាគមអាជ្ញាធរមូលដ្ឋានក្នុងការសម្របសម្រួល ការផ្ទេរ និងការអនុវត្តតាមបទពិសោធន៍ល្អៗនានា ។
- បង្កើតបណ្តាញអាជ្ញាធរ និងសមាគមអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងវិទ្យាស្ថានអប់រំនានាដើម្បីធ្វើការផ្លាស់ប្តូរ និងផ្ទេរបទពិសោធន៍ល្អៗស្តីពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅក្នុងតំបន់ ។

## គុណតម្លៃនៃគម្រោង

យើងជឿជាក់ទៅលើការចូលរួមរបស់ប្រជាពលរដ្ឋថាជាផ្នែកស្នូលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រដ្ឋបាលមូលដ្ឋាន ។ បញ្ហានានា ដែលជួបប្រទះដោយក្រុមប្រជាពលរដ្ឋទន់ខ្សោយ មានជាអាទិ៍ ភាពក្រីក្រ ការទទួលបាននូវសេវាសាធារណៈ ព័ត៌មាន និងសុខមាលភាពផ្នែកសេដ្ឋកិច្ចនឹងត្រូវដោះស្រាយបានល្អប្រសើរ ប្រសិនបើរដ្ឋាភិបាលមូលដ្ឋាន និងសមាជិកសហគមន៍របស់ខ្លួនចូលរួមក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្តជាមួយគ្នា ។

យើងឱ្យតម្លៃថា ភាពប្រសើរឡើងនៃស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋជាពិសេសក្រុមជនទន់ខ្សោយក៏ពឹងផ្អែកផងដែរ ទៅលើភាពប្រសើរឡើងនៃអភិបាលកិច្ចស្ថាប័ន បរិស្ថានទីប្រជុំជន ការលើកកម្ពស់ការវិនិយោគ និងសារពើពន្ធ ។

យើងគោរពដល់ភាពខុសៗគ្នា ។ ក្នុងពេលដែលយើងជំរុញឱ្យមានការចែករំលែកមេរៀនពីគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យប្រសើរឡើងនៃគុណភាពសេវាសាធារណៈរបស់រដ្ឋាភិបាលមូលដ្ឋាន យើងក៏ទទួលស្គាល់នូវស្ថានភាពខុសគ្នានៃវប្បធម៌ សង្គម និងនយោបាយផងដែរ ។ ភាពខុសគ្នាទាំងនេះ ក៏ជាមាគ៌ាមួយ ដើម្បីសម្រេចបាននូវការអនុវត្តប្រកបដោយចិរភាពក្នុងបរិបទវិមជ្ឈការ ។

## ការផ្ទេរ និងការអនុវត្តតាមបទពិសោធន៍ល្អៗនានា

បទពិសោធន៍ល្អចាំបាច់ត្រូវ (១) អាចធ្វើតាមបាន បង្កើតបានជាលទ្ធផល និងតាមរយៈមធ្យោបាយអភិបាលកិច្ចល្អ និងមាននិរន្តរភាព និង (២) ក្របខ័ណ្ឌ និងមធ្យោបាយនានាដែលអនុវត្តដោយរដ្ឋាភិបាលមូលដ្ឋាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ ។

បទពិសោធន៍ល្អៗរបស់យើងគ្របដណ្តប់លើប្រធានបទចំនួនបួនៈ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងធ្វើសេចក្តីសម្រេចចិត្ត អភិបាលកិច្ចស្ថាប័ន បរិស្ថានទីប្រជុំជន និងការលើកកម្ពស់ការវិនិយោគ និងការគ្រប់គ្រងសារពើពន្ធ ។

ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍ បានជ្រើសរើសបទពិសោធន៍ល្អៗចំនួន១៦ ពីបណ្តាប្រទេសជាដៃគូ និងសម្របសម្រួលឱ្យមានការផ្ទេរ និងការអនុវត្តតាមនូវសកម្មភាពទាំងនេះក្នុងបណ្តាទីក្រុងមួយចំនួនខាងក្រោម ៖

កម្ពុជា ៖ សង្កាត់ចោមចៅ និងក្រុងកំពត

ឥណ្ឌូនេស៊ី ៖ Kupang, Pangkal Pinang, Tarakan, and Wakatobi

ហ្វីលីពីន ៖ Bacolod city, Misamis Oriental (ManluNa and BinKiSu), One Pangasinan Alliance of LGUs

ថៃ ៖ Chiang Rai City, Songkla City, Yala City, and Pakkret

វៀតណាម ៖ Da Nang, Tra Vinh, Vinh

ក្រុមជំនាញការអភិបាលកិច្ចមូលដ្ឋាន និងអ្នកសម្របសម្រួលមួយចំនួន នឹងជួយបណ្តាទីក្រុងសាកល្បងទាំងនេះ ក្នុងដំណើរការផ្ទេរបទពិសោធន៍ល្អៗព្រមទាំងធ្វើការតាមដាន និងត្រួតពិនិត្យផងដែរ ។

សម្រាប់ព័ត៌មានលម្អិតស្តីពីបទពិសោធន៍ល្អៗ សូមមើលគេហទំព័រ http://www.DELGOSEA.eu.

## បណ្តាលទ្ធផលរបស់គម្រោង

គម្រោងមានរយៈពេល៣០ខែ ចាប់ពីខែមីនា ឆ្នាំ២០១០ ដល់ខែសីហា ឆ្នាំ២០១២ ។ នៅពេលបញ្ចប់គម្រោង យើងរំពឹងថា ការអនុវត្តតាមបទពិសោធន៍ល្អៗនៃទីក្រុងសាកល្បងនានា នឹងនៅតែបន្តមានឥទ្ធិពលល្អ និងជាក់ស្តែងសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ។

មុនពេលបញ្ចប់គម្រោង ការតាមដាន និងវាយតម្លៃដើម្បីកំណត់លទ្ធផល និងបញ្ហាប្រឈមនានាក្នុងការផ្ទេរ និងការអនុវត្តតាមបទពិសោធន៍ល្អៗ នឹងត្រូវធ្វើឡើងនៅទីក្រុងសាកល្បងទាំងនេះ ។ ទីក្រុងសាកល្បងទាំងនេះក៏នឹងរៀបចំផែនការសកម្មភាពរបស់ខ្លួន ដើម្បីធានាដល់និរន្តរភាពក្នុងការអនុវត្តតាមបទពិសោធន៍ល្អៗ ដែលខ្លួនបានជ្រើសរើស ។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ យើងសង្ឃឹមថាបណ្តាញដ៏រឹងមាំមួយ នៃសមាគមរដ្ឋាភិបាលមូលដ្ឋាននឹងបន្តគាំទ្រដល់រដ្ឋាភិបាលមូលដ្ឋានក្នុងដំណើរការធ្វើផែនការអនុវត្ត និងធ្វើឱ្យមានចិរភាពនូវយុទ្ធសាស្ត្រ និងសកម្មភាពនៃការអនុវត្តល្អ និងប្រើប្រាស់បទពិសោធន៍ទាំងនេះ ជាមួយនឹងទីក្រុងជាដៃគូដទៃៗទៀត ។